ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២៨០២ សរ៍ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី៧

ក្រសួងមហាផ្ទៃមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងសាធារណជនមេត្តាជ្រាបថា ក្រសួងមហាផ្ទៃនឹងរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី៧ ក្រោមប្រធានបទ "សិទ្ធិសេរីភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងបរិបទឌីជីថល" ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ១៤កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦ ខាងមុខនេះ នៅទីស្តីការក្រសួងមហាផ្ទៃ(អគារ S)។ ការរៀបចំវេទិកានេះធ្វើឡើងក្នុងគោលបំណងដើម្បីពង្រឹង និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋដែលជាមូលដ្ឋានគ្រឹះជានាដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងបរិយាបន្ន ជាពិសេសដើម្បីលើកស្ទួយសិទ្ធិសេរីភាពសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងរួមគ្នាពិភាក្សាពិគ្រោះយោបល់និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលឱ្យមានភាពល្អប្រសើរបន្ថែមទៀត។

អាស្រ័យហេតុនេះ សូមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានបំណងចូលរួមក្នុងវេទិកានេះ សូមធ្វើការចុះឈ្មោះចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៦ តាមរយៈតំណភ្ជាប់ https://forms.gle/xsaKFZzVzmH944mXA ឬតាមការស្កេន QR កូដ ដូចមានជូនភ្ជាប់ដូចខាងក្រោម។

**កំណត់សម្គាល់៖**

ដោយសារកន្លែងរៀបចំវេទិកានេះមានចំនួនកំណត់ ដូចនេះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះឈ្មោះចំនួន ៣០០(បីរយ)នាក់ ដំបូងនឹងត្រូវបានផ្តល់អាទិភាពក្នុងការចូលរួម។

ថ្ងៃ........ខែ........ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី........ខែកក្កដា ឆ្នាំ២០២៦
ក្រសួងមហាផ្ទៃ

សូមស្កេនទីនេះដើម្បីចុះឈ្មោះ

**ព័ត៌មានបន្ថែម**
សូមទំនាក់ទំនងតាមរយៈទូរសព្ទលេខ៖
០១៧ ៧៧៥ ១៣៨ / ០៩៥ ៩៤៥ ៥៥៦